# ចៅក្រមអង្គបុរេជំនុំជម្រះ ជាតិ និងអន្តរជាតិ ខ្វែងគំនិតគ្នានៅក្នុងសំណុំរឿង ០០៣ ជាថ្មីម្តងទៀត

អែនហេន ខែល, ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣

ប្រែសម្រួលដោយ វ៉ាន់ថាន់ ពៅដារ៉ា

អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានខ្វែងគំនិតគ្នារវាងចៅក្រមអន្តរជាតិ និងចៅក្រមជាតិជាថ្មីទៀត លើសំណុំរឿង ០០៣ ដែលមានភាពចម្រូងចម្រាស់គ្នា ដោយបដិសេធនូវបណ្តឹងឧទ្ធរណ៍របស់អ្នកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណី ដែលទទួលបានការទាត់ចោលម្តងរួចហើយកាលពី១៨ខែមុន ក្រោយពីបណ្តឹងនេះជាប់គាំងនោះ ។[១] សេចក្តីសម្រេចនេះស្តែងឲ្យឃើញបន្ថែមទៀតនូវភាពមិនប្រក្រតីលើនីតិវិធីក្នុងការគ្រប់គ្រងសំណុំរឿង និងធ្វើឲ្យមានកង្វល់ឡើងវិញអំពីសមត្ថភាពរបស់តុលាការក្នុងការចាត់ការកិច្ចស៊ើបសួរដែលនៅសេសសល់ ដោយឯករាជ្យ និងមិនលំអៀង ។

កង់ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និងអតីតសហភាគីរបស់គាត់ គឺចៅក្រម Siegfried Blung បានសម្រេចបិទការស៊ើបអង្កេតលើសំណុំរឿង ០០៣ភ្លាមៗ ដោយចេញតែសេចក្តីថ្លែងការណ៍ព័ត៌មានមួយល្បះប៉ុណ្ណោះ[២] ហើយពុំបានជូនដំណឹងជនរងគ្រោះអំពីសិទ្ធិដែលនឹងផុតកំណត់ក្នុងចូលរួមក្នុងដំណើរការនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងការដាក់សំណើសុំចំណាក់ការស៊ើបអង្កេតចុងក្រោយ ។ ជនរងគ្រោះពីរបីនាក់មានលទ្ធភាពដាក់ពាក្យបណ្តឹងនៅក្នុងអំឡុងពេលនៃការកំណត់រយៈ១៥ថ្ងៃដែលច្បាប់ផ្តល់ជូន[៣] ហើយអ្នកដាក់បណ្តឹងដែលដឹងជាសាធារណៈទាំងនោះត្រូវបានទាត់ចោលដោយសហចៅក្រមសេ៊បអង្កេត ។ ដោយទទួលបានបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹង Rob Hamill ដែលបងរបស់គាត់ត្រូវបានឃោឃាដើងទឹកដែលស្ថិតក្រោមបញ្ជាការរបស់ជនសង្ស័យក្នុងសំណុំរឿងនេះ ចាប់ជាអ្នកទោស និងក្រោយមកត្រូវបានសម្លាប់ចោលនោះ អង្គបុរេជំនុំជម្រះពុំអាចឈានដល់ការសម្រេចទេ ដោយសារតែមានការខ្វែងគំនិតគ្នារវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ។ យោបល់ដោយឡែករបស់ចៅក្រមអន្តរជាតិបានបន្ទោសសហចៅក្រមស៊ើបអង្កេត ពីភាពមិនស៊ីសង្វាក់

---

[១] ការពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ពន្ធ័នឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទទួលយកបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣) (អំណោះតទៅហៅថា ការពិចារណារបស់អង្គបុរេជំនុំជម្រះឆ្នាំ២០១៣) ។

[២] សូមមើល សេចក្តីការណ៍ព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣) ។

[៣] វិធានផ្ទៃក្នុង, វិធាន ២៣ ស្ទួន២ ។

នៅក្នុងការដោះស្រាយកិច្ចស៊ើបសួរ ដោយប្រៀបធៀបនឹងរបៀបស៊ើបអង្កេតលើសំណុំរឿង ០០១ និង០០២ ដែលបានធ្វើឡើងកន្លងមក រួមទាំងការខកខានក្នុងការចង្អុលបង្ហាញជនសង្ស័យដែលត្រូវចោទប្រកាន់ ការខកខានក្នុងការជូនដំណឹងជនរងគ្រោះឲ្យបានទាន់ពេលវេលា ដើម្បីឲ្យជនរងគ្រោះអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត ការខកខានក្នុងការទទួលស្គាល់មេធាវីរបស់ដើមបណ្តឹង និងក្នុងការជូនដំណឹងដល់មេធាវីអំពីឯកសារនៅក្នុងសំណុំរឿង ឬផ្តល់សិទ្ធិទទួលបានការមើលសំណុំរឿង ព្រមទាំង«ការពន្យាពេលដែលពុំមានការពន្យល់ឲ្យបានជាក់លាក់នៅក្នុងដំណើរការទទួលយកឯកសារ និងដាក់ឯកសារចូលក្នុងសំណុំរឿង» ។[៤]

អ្នកដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត គឺមិនត្រូវបានបញ្ចេញឈ្មោះទេ ។ ដើមបណ្តឹងម្នាក់នេះ ត្រូវបានបង្ខំឲ្យរៀបការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយប្តីរបស់របស់ខ្លួនត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់នៅការដ្ឋានសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង (ទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០៣) មុននឹងត្រូវបានធ្វើទារុណកម្ម និងសម្លាប់ចោលនៅមន្ទីរសន្តិសុខ ស-២១ ។ បើទោះបីជាដេមបណ្តឹងម្នាក់នេះត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០១ និង០០២រួមមកហើយក៏ដោយ សហចៅក្រមស៊ើបអង្កេតនៅតែផ្តល់ហេតុផលថា ដើមបណ្តឹងម្នាក់នេះពុំទទួលរងផលប៉ះពាល់ដោយផ្ទាល់ដោយឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងប្តីរបស់ខ្លួនទេ ផ្ទុយទៅវិញគឺដោយបច្ច័យផ្សេង ពោលគឺការងារធ្ងន់ដែលត្រូវបានបង្ខំឲ្យធ្វើរបស់ប្តីដើមបណ្តឹងនោះ ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញទៀតថា វា«មិនជាទំនងប៉ុន្មានទេ» ដែលថា ដើមបណ្តឹងម្នាក់នេះ តាមពិតទៅ បានទទួលរងការឈឺចាប់ខាងផ្លូវចិត្តដោយសារតែការបង្ខំឲ្យធ្វើការជាទម្ងន់របស់ប្តីខ្លួន កាលពី៣៨ឆ្នាំកន្លងទៅនោះ ហើយសន្និដ្ឋានថា ដើមបណ្តឹងម្នាក់នេះប្តឹងទាមទារ«ដោយផ្អែកលើការឲ្យយោបល់ដែលមិនសមហេតុពីភាគីទី៣» ។នៅទីបញ្ចប់ សហចៅក្រហមស៊ើបអង្កេតបាននិយាយថា ដើមបណ្តឹងនេះមិនគួរនឹងទទួលយកទេពីព្រោះខ្លួនគឺជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង០០២ រួចទៅហើយ ។[៥]

---

[៤] ការពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទទួលយកបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill សំណុំរឿងលេខ 003/07-09-ECCC/OCIJ (PTC02) យោបល់របស់ចៅក្រម Lahuis and Downing វាក្យខណ្ឌ៣-១៦ (ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១) (សម្រេចថា បណ្តឹងឧទ្ធរណ៍អាចយកមកពិភាក្សាបានពីព្រោះសហចៅក្រមស៊ើបអង្កេតបានដាក់ដីកាសម្រេចទាត់ចោលដើមបណ្តឹងរដ្ឋប្បវេណីដែលរការជំទាស់ជំនួសវិញនៅពេលដែលការជំទាស់នឹងភាពមានចន្លោះត្រូវបានធ្វើបណ្តឹងឧទ្ធរណ៍) ។

[៥] ដីកាសម្រេចលើភាពអាចទទួលយកបាននូវបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, សំណុំរឿងលេខ 003/07-09-ECCC/OCIJ, វាក្យខណ្ឌ ៥,៩,១០ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១) ។

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងនេះកាលពីឆ្នាំ២០១១ បាន ចង្អុលបង្ហាញថា វាពុំមានការបន្ទន់នូវទស្សនៈយល់ឃើញតាំងពីពេលចេញសេចក្ដីសម្រេចលើ Rob Hamill មកម្ល៉េះ ។ ដោយសារតែអង្គបុរេជំនុំជម្រះពុំអាចឈានដល់សេចក្ដីសម្រេចជាឯកច្ឆន្ទ អនុលោមតាមវិធានរបស់តុលាការ សេចក្ដីសម្រេចទាត់ចោលការដាក់បណ្ដឹងរបស់ដើមបណ្ដឹងដោយសហចៅក្រមស៊ើបអង្កេតនៅតែមានប្រសិទ្ធិភាព ។ ដោយផ្ទុះបញ្ចាំងលើហេតុផលដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ Rob Hamill យោបល់ដោយឡែករបស់ចៅក្រមជាតិនៅអង្គបុរេជំនុំជម្រះអះអាងថា ដោយសារតែសហចៅក្រមស៊ើបអង្កេតពុំទាន់ចោទប្រកាន់នរណាម្នាក់នៅឡើយក្នុងសំណុំរឿង ០០៣ «ទើបពុំមានជនត្រូវចោទដែលត្រូវទទួលខុសត្រូវលើដំណោះស្រាយដែលស្វែងរកសម្រាប់ជួសជុលការខូចខាតដែលបង្កដល់ជនរងគ្រោះ ហើយអាស្រ័យហេតុនេះ ការទាត់ចោលការសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅដំណាក់កាលនេះ គឺពុំរំលោភលើសិទ្ធិរបស់ជនរងគ្រោះទេ» ។[៦]

ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិ Downing និង Chung បានយកតាមការកត់សម្គាល់ទាំងអស់នៅក្នុងសេចក្ដីលើបណ្ដឹងឧទ្ធរណ៍របស់ Rob Hamill ស្ដីអំពីការកើតមានឡើងនូវភាពមិនប្រក្រតីផ្នែកនីតិវិធី និងភាពមិនស៊ីសង្វាក់នៅក្នុងកិច្ចការរបស់សហចៅក្រមស៊ើបអង្កេត ។ លើសពីនេះទៀត ចៅក្រមទាំងពីរបានរកឃើញភាពមានចន្លោះផ្នែកនីតិវិធីបន្ថែមទៀត ដែលតាមទស្សនៈរបស់ខ្លួន គឺត្រូវឈានដល់ការសម្រេចមោឃៈភាព ដោយសារតែ «ផលប៉ះពាល់របស់វាមានលក្ខណៈផ្ទុយគ្នា» លើសិទ្ធិរបស់ភាគី ៖ ទាំងការដាក់បណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទាំងឯកសារដែលគាំទ្រដល់បណ្ដឹងគឺជាផ្នែកខ្លះនៅក្នុងសំណុំរឿង ដែលនាពេលនោះត្រូវទាត់ចោល ។ «ហេតុដូច្នេះ វាទំនងត្រូវបានសហចៅក្រមស៊ើបអង្កេតចេញសេចក្ដីសម្រេចដែលរងការជំទាស់ដោយពុំទទួលយកបណ្ដឹង និងពុំជូនដំណឹងដល់សហព្រះរាជអាជ្ញា និងជនត្រូវចោទ» ដោយជៀសវាងនូវ «របបនីតិវិធីដែលមានរួចមកហើយតាមរយៈវិធានផ្ទៃក្នុងព្រមទាំងការធានាជាមូលដ្ឋានលើដំណើរការក្ដីប្រកបដោយយុត្តិធម៌ ដែលចែងឡើងជាស្តង់ដាទទួលស្គាល់ជាអន្តរជាតិ ។»[៧] ភាពមិនប្រក្រតីថ្មីនេះ «ផ្ទុះបញ្ចាំងឲ្យឃើញនូវគំរូនៃការប្រព្រឹត្តដែលទទួលយកដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣» ដែល «ធ្វើឲ្យមានមន្ទិលសង្ស័យលើចេតនារបស់

[៦] ការពិចារណារបស់អង្គបុរេជំនុំជម្រះឆ្នាំ២០១៣, កំណត់សម្គាល់លេខ១ខាងដើម, យោបល់ដោយឡែករបស់ចៅក្រម ប្រាក់, ន័យ និង ហួត, វាក្យខណ្ឌ ១៥ ។

[៧] ស្អួន យោបលដោយឡែករបស់ចៅក្រម Downing និង Chung, វាក្យខណ្ឌ ១-៨ ។

ចៅក្រមក្នុងការបើកកិច្ចដំណើរនីតិវិធីតាមរបៀបមួយដែលប្រកបដោយតម្លាភាព ត្រឹមត្រូវ និងអាចគតាំងបាន ដែលនឹងធានាដល់ការគោរពសិទ្ធិរបស់ភាគី និងអ្នកចូលរួមនៅកិច្ចដំណើរការនោះ» ។[៨]

ដោយចៅក្រមជាតិ និងអន្តរជាតិពុំយល់ព្រមបញ្ជូនសំណុំរឿងត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញដើម្បីធ្វើការពិចារណាជាថ្មី ដោយសារតែផលវិភាកដែលកើតចេញពីភាពមានចន្លោះផ្នែកនីតិវិធីទាំងនោះ គឺជាលើកទី១ហើយ ដែលចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះដោះស្រាយលើខ្លឹមសារនៃហេតុផលដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ។ ចៅក្រមអន្តរជាតិបានកត់សម្គាល់ថា ទាំងដើមបណ្តឹងឧទ្ធរណ៍ ទាំងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលធ្លាប់បានទទួលយកដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ និង ០០២ បានពឹងផ្អែកលើ«ការឈឺចាប់ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកគ្រួសារផ្ទាល់របស់ខ្លួន ដោយរួមបញ្ចូលទាំងប្តីឬប្រពន្ធរបស់ខ្លួនទៀតផង» ។ ក្នុងការសម្រេចផ្ទុយ ដែលថារបួសស្នាមរបស់ដើមបណ្តឹង ពុំឆ្លើយតបនឹងលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ការទទួលយកនៅក្នុងសំណុំរឿង ០០៣នោះ គឺសហចៅក្រមស៊ើបអង្កេតមិនបានយកចិត្តទុកដាក់លើការសម្រេចពីមុនៗរបស់តុលាការ និងបានរំលោភលើសិទ្ធិរបស់ភាគី«ក្នុងការទទួលបាននូវភាពជាក់លាក់របស់ច្បាប់ និងភាពស្មើគ្នាចំពោះមុខច្បាប់» ។ លើសពីនេះទៀត ចៅក្រមអន្តរជាតិបានរកឃើញនូវចំណងទាក់ទងដែលសហចៅក្រមស៊ើបអង្កេតសម្រេចថា មានតែជនរងគ្រោះក្នុងចំណងលោហិតជិតស្និតប៉ុណ្ណោះ មានសិទ្ធិក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយមិនមែនញាតិលោហិតឆ្ងាយនោះទេដែលមានសិទ្ធិនេះ ដែលវាខុសមិនត្រឹមតែនឹងគោលបំណងរបស់វិធានផ្ទៃក្នុងប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងខុសនឹងការអនុវត្តន៍លក្ខណៈជាតិ និងអន្តរជាតិទៀតផង ។[៩] ចុងបញ្ចប់ ចៅក្រមអន្តរជាតិបាននិយាយថា ស្តង់ដានៃភស្តុតាងដូចដែលយកមកអនុវត្តនេះខ្វះការឲ្យហេតុផលច្បាស់លាស់ និងការសន្និដ្ឋានដែលថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិទទួលឲ្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងច្រើនផ្សេងពីគ្នានោះ «គឺពុំមានក្នុងមូលដ្ឋានច្បាប់ ឬនៅក្នុងការឲ្យហេតុផលពីមុនៗទេ ហើយបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះទៀតផង» ។[១០]

---

[៨] សូន យោបល់ដោយឡែករបស់ចៅក្រម Downing និង Chung, វាក្យខណ្ឌ ៩ ។

[៩] សូន យោបល់ដោយឡែករបស់ចៅក្រម Downing និង Chung, វាក្យខណ្ឌ ១៨-២៦ ។

[១០] សូន យោបល់ដោយឡែករបស់ចៅក្រម Downing និង Chung, វាក្យខណ្ឌ ២៧-៣៧ ។

ដោយសារតែអង្គបុរេជំនុំជម្រះដែលមានការខ្វែងគំនិតនេះ មិនអាចផ្តល់ជូនដើមបណ្តឹងខទ្ទរណ៍នូវការដោះស្រាយចំពោះការពិចារណាដោយខ្វះចន្លោះរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំរបស់ដើមបណ្តឹង ទើបចៅក្រមអន្តរជាតិជំរុញឲ្យសហចៅក្រមស៊ើបអង្កេតបច្ចុប្បន្ន អនុវត្តសិទ្ធិអំណាចដែលខ្លួនមានដើម្បីពិចារណាលើសំណើសុំនោះឡើងវិញ ។[១១] ទោះបីជាយ៉ាងនេះក្តី ដូចដែលបានកត់សម្គាល់ដោយចៅក្រមអញ្ចឹង គឺរឿងនេះធ្លាប់បានកើតមានរួចមកហើយ ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបំរុង Laurent Kasper-Ansermet (ឡូរ៉ង់ កាស្ពឺ-អានសើមេត) ចូលកាន់តំណែងជំនួសឲ្យចៅក្រម Blung (ប្លុង) លោកបានពិចារណាសំណើសុំនោះឡើងវិញ ដោយរកឃើញថា សំណើសុំនោះបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវចាំបាច់ដែលអាចទទួលយកបាន និងបានផ្តល់ជូននូវសិទ្ធិទទួលបានឯកសារក្នុងសំណុំរឿងទៀត[១២] ដោយបានធ្វើឲ្យបណ្តឹងខទ្ទរណ៍របស់ដើមបណ្តឹង អាចយកមកពិភាក្សាបានយ៉ាងត្រឹមត្រូវ ។[១៣] ទោះបីជាយ៉ាងនេះក្តី សេចក្តីសម្រេចរបស់ចៅក្រម កាស្ពឺ-អានសើមេត ពុំមានឥទ្ធិពលជាក់ស្តែងទេ គឺដោយសារតែរដ្ឋាភិបាលកម្ពុជាមិនព្រមទទួលស្គាល់ការតែងតាំង និងសិទ្ធិអំណាចក្នុងការចាត់វិធានការរបស់លោកចៅក្រម ។[១៤] បុគ្គលិកជាតិបានបដិសេធដោយបែបក្នុងការអនុវត្តសេចក្តីសម្រេចនេះ ដោយរាប់បញ្ចូលទាំងការសម្រេចទទួលយកការពិចារណាឡើងវិញ លើសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី Rob Hamill (រ៉ប់ ហាមីុល) និងផ្តល់ជូនមេធាវីរបស់ដើមបណ្តឹងរូបនេះនូវសិទ្ធិទទួលបានឯកសារនៅក្នុងសំណុំរឿង ០០៣ ទៀតផង ។[១៥]

---

[១១] ស្ទួន យោបល់ដោយឡែករបស់ចៅក្រម Downing និង Chung, វាក្យខណ្ឌ ៣៨ ។

[១២] ដីកាសម្រេចស្តីពីការពិចារណាឡើងវិញលើភាពអាចទទួលយកបាននូវបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, វាក្យខណ្ឌ ៣៤ (ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២) ។

[១៣] ការពិចារណារបស់អង្គបុរេជំនុំជម្រះឆ្នាំ២០១៣, កំណត់សម្គាល់លេខ១ខាងដើម, យោបល់ដោយឡែករបស់ចៅក្រម Downing និង Chung, វាក្យខណ្ឌ ៣៩ ។

[១៤] អង្គការសហប្រជាជាតិ និងចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះ ពុំយល់ព្រម ។ សូមមើល សេចក្តីថ្លែងការណ៍ដែលភ្ជាប់នឹងអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីកម្ពុជា, សហចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ថ្ងៃទី២០ ខែមករា ឆ្នាំ២០១២), យោបល់របស់ចៅក្រម Downing និង Chung, នៃអង្គបុរេជំនុំជម្រះ លើភាពមិនយល់ស្របគ្នារវាងសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៧២ សំណុំរឿងលេខ 003/16-12-2011-ECCC/PTC, វាក្យខណ្ឌ៣៣ (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២) ។

[១៥] សូមមើល កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបំរុងជូនចំពោះភាគីស្តីពីភាពមិនដំណើរការជាក់ស្តែងនៅក្នុងអ.វ.ត.ក ដែលភ្ជួរកិច្ចស៊ើបអង្កេតត្រឹមត្រូវក្នុងសំណុំរឿង ០០៣ និង ០០៤, សំណុំរឿងលេខ 003/07-09-2009-ECCC-OCIJ និង សំណុំរឿងលេខ 004/07-09-2009-ECCC-OCIJ, វាក្យខណ្ឌ៣៩-៤០ (ថ្ងៃទី២១ ខែមិនា

អាស្រ័យហេតុនេះ វាមិនសូវជាទំនងទេដែលថា សេចក្តីសម្រេចណាមួយរបស់ចៅក្រម កាស្ទី-អានសើមេត រួមទាំងការបន្តការស៊ើបអង្កេតលើសំណុំរឿង០០៣នោះ នឹងត្រូវបានគោរពតាម លុះត្រាតែចៅក្រមMark Harmon(មាក់ហាម៉ុន) ដែលទទួលតំណែងបន្តនោះ ទទួលយកសេចក្តីសម្រេចមកអនុវត្ត ។ សេចក្តីសម្រេចថ្មីរបស់អង្គបុរេជំនុំជម្រះ បានប្រកាន់យកលំនាំពីមុន ដោយសារតែ ទស្សនៈរបស់ចៅក្រមជាតិនៅតែព្យាយាមលើកហេតុផលដដែលៗ នោះគឺភាពខ្វះខាតក្នុងការទទួលបានអំណាចរបស់ចៅក្រម កាស្ទី-អានសើមេត ដែលបានធ្វើឲ្យរូបចៅ ពុំមានសិទ្ធចាត់កិច្ចស៊ើបសួរ ។[16] ភាពគ្មានសុឆន្ទៈបន្តទៀតរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំ ក្នុងការទទួលស្គាល់ និងដោះស្រាយភាពមានចន្លោះផ្នែកនីតិវិធីដែលជាក់ស្តែង និងរីករាលដាល ទាក់ទងនឹងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ អាចធ្វើឲ្យកើនឡើងនូវភាពមន្ទិលសង្ស័យ ដែលថា សំណុំរឿងនេះនឹងត្រូវអនុញ្ញាតឲ្យចាត់ការបន្ត ដោយអនុលោមតាមវិធានផ្ទៃក្នុង និងស្តង់ដារអន្តរជាតិរបស់តុលាការ ទោះបីជាមានសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីចូលមកកាន់តំណែងក៏ដោយ ។

---

ឆ្នាំ២០១២) (ក៏ប៉ុន្តែ កំណត់សម្គាល់ថា បុគ្គលិកអន្តរជាតិដែលគោរពតាមបង្គាប់របស់ចៅក្រម និង (យ៉ាងហោចដោយបណ្តោះអាសន្ន) "ផ្តល់សិទ្ធិទទួលបានឯកសារមានប្រសិទភាព"ដល់មេធាវី) ។

[16] ការពិចារណារបស់អង្គបុរេជំនុំជម្រះឆ្នាំ២០១៣, កំណត់សម្គាល់លេខ១១ខាងដើម, យោបល់ដោយឡែករបស់ចៅក្រម ប្រាក់, ន័យ និង ហ្វូត, វាក្យខណ្ឌ ១៦ (ដោយយោងជាពិសេសលើសិទ្ធិរបស់ខ្លួនក្នុងការជូនដំណឹងដល់ជនសង្ស័យពីបទចោទប្រឆាំងនឹងជនសង្ស័យ) ។